ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសជប៉ុន
លេខៈ / ២២/១៥ តក

តូក្យូ, ថ្ងៃទី ០១ ខែឧសភា ឆ្នាំ ២០១៥

សូមគោរពជូន
ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

**កម្មវត្ថុ:** ស្ថានភាពសេដ្ឋកិច្ចជប៉ុន និងសកម្មភាពការងារទីប្រឹក្សាពាណិជ្ជកម្មប្រចាំខែមីនា-មេសា២០១៥។

ខ្ញុំបាទមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបអំពីស្ថានភាពសេដ្ឋកិច្ច និងសកម្មភាពការងារទីប្រឹក្សាពាណិជ្ជកម្មប្រចាំខែមីនា-មេសា ២០១៥ ដូចខាងក្រោម:

**១-ស្ថានការណ៍សេដ្ឋកិច្ច:**

**ក-សេដ្ឋកិច្ចជប៉ុន :**

នៅខែមេសា ២០១៥នេះ សភាជប៉ុន (Diet) បានអនុម័តថវិកាឆ្នាំ២០១៥ ចំនួន ¥96.34 trillion ស្មើនឹង US$ 803.45 billion) ដើម្បីជួយជម្រុញសេដ្ឋកិច្ចឲ្យងើបឡើងវិញ។ការអនុម័តថវិកានេះបន្ទាប់ពីរដ្ឋសភា (House of Representatives) បានផ្តល់ការយល់ព្រមកាលពីខែមីនាកន្លងទៅ។s

ដោយឡែក រដ្ឋាភិបាលលោក Shinzo Abe ក៏បានយល់ព្រមលើគម្រោងថវិកាបណ្តោះអាសន្ន ¥ 5.76 trillion ស្មើនឹង US$ 48.3 billion សម្រាប់ការផ្តល់មូលនិធិលើ Subsidy ទៅ local government ចំនួន ¥ 2.97 trillion សម្រាប់ការចំណាយលើសន្តិសុខសង្គម ចំនួន ¥2.16 trillion និងសម្រាប់ការចំណាយលើការការពារជាតិ (Defence related spending) ចំនួន ¥ 155.2 billion។

ពាក់ព័ន្ធនឹងសេដ្ឋកិច្ចវិញ មជ្ឈមណ្ឌលសម្រាប់ការសិក្សាសេដ្ឋកិច្ចជប៉ុន បានចេញនូវទិន្នន័យកំណើនសេដ្ឋកិច្ចជប៉ុនប្រចាំខែកុម្ភៈថា កំណើនសេដ្ឋកិច្ច បានធ្លាក់ចុះ -2.1% ដែលជាការធ្លាក់ចុះលើកទី1 ក្នុងរយៈពេល ៣ខែ ដោយសារតែការនាំចេញ បានធ្លាក់ចុះ 6.5%, វិនិយោគមូលធនឯកជន ធ្លាក់ចុះ 1.8% បន្ទាប់ពីបានកើនយ៉ាងខ្លាំងនៅខែមករា និងការធ្លាក់ចុះនូវ Consumption 0.4% ក្នុងរយៈពេល ៣ខែជាប់ៗគ្នា។

ជាមួយគ្នានេះដែរ អង្គការ OECD (Organization for Economic Cooperation & Development) បានព្យាករណ៍កំណើនសេដ្ឋកិច្ចជប៉ុនថា នៅឆ្នាំ២០១៥ នឹងមានកំណើន 1% និងឆ្នាំ២០១៦ នឹងទទួលបានកំណើន 1.4% ដែលស្របគ្នាទៅនឹងការរំពឹងទុករបស់ធនាគារកណ្តាលជប៉ុន BOJ ថានឹងសម្រេចបាននូវអត្រាអតិផរណា 2% នៅឆ្នាំ ២០១៦ ដោយសារតែការធ្លាក់ចុះនៃតម្លៃប្រេង កំណើន Consumption ក្នុងស្រុក និងការវិនិយោគ។ ប៉ុន្តែទោះជាយ៉ាងណា អង្គការ OECD បានស្នើឲ្យរដ្ឋាភិបាលជប៉ុន អនុវត្តនយោបាយកែទម្រង់រចនាសម្ព័ន្ធ (Structural Reform) ឲ្យបានឆាប់ ជាមួយនឹងការបញ្ចប់កិច្ចព្រមព្រៀងដៃគូអន្តរប៉ាស៊ីហ្វិក TPP ។

**ខ-ស្ថានភាពប្រាក់យ៉េន (Source: Bank of Japan):**

**ខែមេសា ២០១៥:** អត្រាប្តូរប្រាក់យ៉េនទល់នឹងដុល្លាអាមេរិក ស្ថិតក្នុងរង្វង់ ¥119.10 ទៅ ¥119.20 / 1 ដុល្លាអាមេរិក។

**គ-ស្ថានភាពការងារ (Source: Ministry of Internal Affairs & Communication of Japan):**

យោងតាមទិន្នន័យការងាររបស់រដ្ឋាភិបាលជប៉ុនថ្ងៃទី០១ ខែឧសភា ២០១៥ បានបង្ហាញថា:

-អ្នកមានការងារធ្វើនៅក្នុងខែមីនា ២០១៥នេះ មានចំនួន 63.19 លាននាក់ នៃកម្លាំងពលកម្មសរុប 65.47 លាននាក់ បានកើន 210,000នាក់ ឬ 0.3% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤។

-អ្នកគ្មានការងារធ្វើនៅក្នុងខែមីនា ២០១៥នេះ មានចំនួន 2.28 លាននាក់ បានថយចុះ 180,000 នាក់ ឬ 7.3% បើធៀបនឹងរយៈពេលដូចគ្នានៃឆ្នាំ២០១៤។

ដូច្នេះ អត្រាអ្នកគ្មានការងារធ្វើសម្រាប់ខែមីនា ឆ្នាំ២០១៥នេះ គឺ 3.4%។

**ឃ-សន្ទស្សន៍សេដ្ឋកិច្ច (Source: Bank of Japan):**

ធនាគារកណ្តាលជប៉ុនបានចេញផ្សាយថ្ងៃទី១៣ ខែមេសា ២០១៥ នូវសន្ទស្សន៍ថ្លៃទំនិញសម្រាប់ខែមីនា ២០១៥ មានដូចខាងក្រោម៖

-សន្ទស្សន៍ថ្លៃទំនិញ បានកើន 0.3% ធៀបនឹងខែកុម្ភៈ

-សន្ទស្សន៍ថ្លៃនាំចេញ បានកើន 0.1% ធៀបនឹងខែកុម្ភៈ

-សន្ទស្សន៍ថ្លៃនាំចូល បានកើន 1.0% ធៀបនឹងខែកុម្ភៈ។

**២-ស្ថានការណ៍ពាណិជ្ជកម្ម:**

**ក-ស្ថិតិពាណិជ្ជកម្មទ្វេភាគីជប៉ុន-កម្ពុជា:** (ខែមីនា ២០១៥)

(Unit: 1,000Yen)

| Activity | 2014 | | | 2015 | | 3 Mon. % change | Mar. -% Change |
|---|---|---|---|---|---|---|---|
| | 2014 | 3-months | March | 3-months | March | | |
| Export | 27,066,733 | 5,040,207 | 1,937,414, | 6,802,783 | 2,658,592 | 35.0 | 37.0 |
| Import | 81,620,826 | 17,710,950 | 6,935,699 | 27,707,097 | 10,538,995 | 56.0 | 52.0 |
| **Total** | 108,687,559 | 22,751,157 | 8,873,113 | 34,509,880 | 13,197,587 | 52.0 | 49.0 |
| **Balance** | **-54,554,093** | **-12,670,743** | **-4,998,285** | **-20,904,314** | **-7,880,403** | **65.0** | **58.0** |

(**Source**: Ministry of Finance of Japan & Customs Office of Japan

អតុល្យភាពជញ្ជីងពាណិជ្ជកម្មជប៉ុនក្នុងខែមីនា ២០១៥ មានទំហំទឹកប្រាក់ ¥7,880.78 million ឬ $78.80 million បានកើន 58% ធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៤។ ទំហំពាណិជ្ជកម្មសរុប ជប៉ុន-កម្ពុជា មាន ¥13,197.58 million ឬ $131.97 million កើន 49% ដែលក្នុងនោះ ជប៉ុននាំចេញទៅកម្ពុជា ចំនួន ¥2,658.59 million ឬ $26.58 million កើន 37% និងនាំចូលពីកម្ពុជាចំនួន ¥10,538.99 million ឬ $105.38 million កើន 49% ធៀបរយៈពេលដូចគ្នានៃឆ្នាំ២០១៤។ បើធៀបនឹងខែមុន ទំហំពាណិជ្ជកម្មកម្ពុជា-ជប៉ុន បានកើនឡើង 25% ។

មុខទំនិញសំខាន់ៗ ជំរុញឲ្យមានកំណើនពាណិជ្ជកម្មជប៉ុន-កម្ពុជា គឺ (១)- ការនាំចេញពីជប៉ុន នូវមុខទំនិញដូចជា: រថយន្ត គ្រឿងចក្រ អេឡិចត្រូនិច ទំនិញឧស្សាហកម្ម វត្ថុធាតុដើមសម្រាប់ផលិតកម្មវាយនភ័ណ្ឌ-ស្បែកជើង និងទំនិញបន្ទាប់បន្សំផ្សេងៗទៀត និង(២)-ការនាំចូលពីកម្ពុជានូវមុខទំនិញ ដូចជា: ទំនិញវាយនភ័ណ្ឌ ស្បែកជើង គ្រឿងបង្គុំរថយន្ត គ្រឿងអេឡិចត្រូនិច ត្បូង-ថ្មមានតម្លៃ និងផលិតផលផ្សេងៗទៀត។ល។

**ខ-ស្ថិតិពាណិជ្ជកម្មជប៉ុន-អាស៊ាន:** (ខែមីនា ២០១៥)

**(Unit: Million of Yen)**

| Activity | March 2014 | March 2015 | Change % |
|---|---|---|---|
| Exports | 962,404 | 1,073,680 | 11.6 |
| Imports | 1,124,289 | 1,089,859 | -3.1 |
| Balance | -161,885 | -16,179 | -90.0 |
| Total Trade | 2,086,693 | 2,163,539 | 6.0 |

(**Source**: Ministry of Finance of Japan & Customs Office of Japan)

ពាណិជ្ជកម្មជប៉ុន-អាស៊ានសរុបក្នុងខែមីនា ២០១៥ មានទំហំ ¥2,163.24 billion ឬ $21.63 billion បានកើនឡើង 6.0% ដែលការនាំចេញ បានកើន 11.6% និងការនាំចូលបានថយចុះ-3.1% និងមានឱនភាពពាណិជ្ជកម្ម ទំហំ ¥ 16.38 billion ឬ$1.63 billion បើធៀបនឹងខែមីនា ២០១៤។ ទំហំពាណិជ្ជកម្មខាងលើនេះ បានកើនឡើង 9.0% បើធៀបនឹងខែកុម្ភៈ ២០១៥ ដែលមានទំហំទឹកប្រាក់ ¥1,975.24 billion ។

**គ-ស្ថិតិពាណិជ្ជកម្មជប៉ុន-ពិភពលោក:** *(ខែមីនា ២០១៥)*

(Unit: millions of YEN, % )

| Activity | March 2014 | March 2015 | Change % |
|---|---|---|---|
| Exports | 6,927,379 | 6,383,276 | 8.5 |
| Imports | 6,698,119 | 7,833,412 | -14.5 |
| Balance | 229,260 | 1,450,136 | - |
| Total Trade | 13,625,498 | 14,216,688 | 6.0 |

(**Source**: Ministry of Finance of Japan & Customs Office of Japan)

សម្រាប់ខែមីនានេះ ជញ្ជីងពាណិជ្ជកម្មរបស់ជប៉ុន ស្ថិតក្នុងអតិរេក (Surplus) ¥ 229.3 billion ដែលជាអតិរេក Surplus លើកទី១ ចាប់ពីឆ្នាំ២០១២មក ដោយសារតែតម្លៃប្រេងឆៅបានធ្លាក់ចុះ បានជម្រុញឲ្យតម្លៃនាំចូលបានធ្លាក់ចុះ។

ទំហំពាណិជ្ជកម្មនៅខែមីនានេះ បានកើន 8.5% ស្មើនឹងចំនួន ¥ 6,927.4 billion ការកើនឡើងនេះបណ្តាលមកពីការកើនឡើងនូវការនាំចេញផលិតផល Automobiles និង Semiconductors ។

ទំហំពាណិជ្ជកម្មនាំចូល បានធ្លាក់ចុះ 14.5% ដែលមានចំនួន ¥ 6,698.1 billion ដោយសារតែការធ្លាក់ចុះនៃការនាំចូលផលិតផលពាក់ព័ន្ធនឹងប្រេង និង Liquefied Natural Gas រួមផ្សំនឹងការធ្លាក់ចុះប្រាក់យ៉េន ដែលនាំឲ្យការនាំចូលកាន់តែថ្លៃជាងមុន ដែលក្នុងនោះ

-ការនាំចូលទៅសហរដ្ឋអាមេរិក បានកើន 21.3% ដែលមានទំហំ ¥1,377.8 billion និងការនាំចូលវិញ បានកើន 23.9% ដែលមានចំនួន ¥774.7 billion

-ការនាំចេញទៅប្រទេសចិន បាន 3.9% ក្នុងទំហំ ¥ 1,201.2 billion និងការនាំចូល បានធ្លាក់ចុះ 19.6% ដែលមានចំនួន ¥1,275.4 billion និង

-ការនាំចេញទៅសហគមន៍អឺរ៉ុប បានកើន 9.1% ដែលមានទំហំ ¥ 704.9 billion និងការនាំចូលបានធ្លាក់ចុះ 5.3% ក្នុងទំហំ ¥ 708.8 billion ។

**៣-សកម្មភាពការងារ:**

- ថ្ងៃទី០១ មេសា : បានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន Matubo Corporation ដែលជាសាខាមួយរបស់ Kobe Steel (KOBELCO) ដើម្បីផ្តល់យោបល់លើឱកាសពាណិជ្ជកម្មនៅកម្ពុជា។
- ថ្ងៃទី០៣ មេសា : បានចូលរួមវេទិកាសម្រាប់អ្នកការទូតលើកទី ២៣ ដែលជាខួបនៃការបញ្ចប់សង្គ្រាមលោកលើកទី២ និងការបង្កើតអង្គការសហប្រជាជាតិ និងការចូលរួមរបស់ជប៉ុនក្នុងការស្វែងរកសន្តិភាព ជាអន្តរជាតិ។
- ថ្ងៃទី០៦ មេសា : បានចូលរួមក្នុងពិធីអបអរសាទរការសម្ពោធដាក់ឲ្យប្រើប្រាស់ស្ពាន Tsubaza រៀបចំដោយស្ថានទូតកម្ពុជាប្រចាំប្រទេសជប៉ុន។
- ថ្ងៃទី០៧ មេសា : បានជួបប្រជុំជាមួយអគ្គនាយកគ្រប់គ្រងទូទៅរបស់ក្រុមហ៊ុន Nagoya Small & Medium Business & Consultation Co., Ltd ដើម្បីពិភាក្សាឱកាសវិនិយោគ និងពាណិជ្ជកម្មនៅកម្ពុជា ដែលលោកនឹងទៅសិក្សាលើផ្នែកវិនិយោគ និងពាណិជ្ជកម្មនៅកម្ពុជានៅក្នុងខែវិច្ឆិកាខាងមុខ។
- ថ្ងៃទី០៩ មេសា : បានចូលរួមក្នុងកិច្ចប្រជុំលើកទី១ របស់ក្រុមការងារផ្នែកវិនិយោគរបស់ AJC និងបានជួបជាមួយតំណាងក្រុមហ៊ុន Business Model Association of Japan ដើម្បីស្នើសុំជួបថ្នាក់ដឹកនាំក្រសួងពាណិជ្ជកម្មដើម្បីស្វែងយល់ពីបច្ចុប្បន្នភាពនៃឱកាសវិនិយោគ និងពាណិជ្ជកម្មសម្រាប់វិស័យសហគ្រាសធុនតូច និងមធ្យមនៅកម្ពុជា។

- ថ្ងៃទី១០ មេសា ៖ បានជួបប្រជុំជាមួយ International Association of Traffic & Safety Science ដើម្បីពិភាក្សាលើការបើកវគ្គបណ្តុះបណ្តាលថ្មីសម្រាប់វគ្គ Leadership Program ឆ្នាំ២០១៥ និងការប្រារព្ធពិធីខួបលើកទី ៣០ឆ្នាំនៃការបង្កើនកម្មវិធីបណ្តុះបណ្តាលនេះ។

- ថ្ងៃទី១៥ មេសា ៖ បានចូលរួមពិធីរៀបចំដោយ Organization for Economic Cooperation & Development ( OECD )។

- ថ្ងៃទី២០ មេសា ៖ បានជួបប្រជុំជាមួយតំណាងក្រុមហ៊ុន Phenix ដើម្បីពិភាក្សាពីទីផ្សារផលិតផលរថយន្តនៅកម្ពុជា និងបានជួបប្រជុំជាមួយសហគមន៍ និងសមាគមនិស្សិតកម្ពុជានៅប្រទេសជប៉ុន និងអ្នកស្ម័គ្រចិត្តជប៉ុន ដើម្បីរៀបចំ the First Cambodia Festival 2015 ដែលបានប្រារព្ធធ្វើពីថ្ងៃទី២៥-២៦ ខែមេសា ២០១៥។

- ថ្ងៃទី០៩ មេសា ៖ បានជួបប្រជុំជាមួយតំណាង Foreign Embassies of Japan Institute for Oversea Investment ( JOI ) ដែលចង់ស្វែងយល់ពីសក្តានុពលវិនិយោគនៅកម្ពុជា។

- ថ្ងៃទី២២ មេសា ៖ បានចូលរួមកិច្ចប្រជុំលើកទី១ របស់ក្រុមការងារផ្នែកទេសចរណ៍ របស់ AJC។

- ថ្ងៃទី២៤ មេសា ៖ បានចូលរួមក្នុងសិក្ខាសាលាផ្សព្វផ្សាយពីកម្មវិធីលទ្ធកម្មរបស់រដ្ឋាភិបាលជប៉ុនសម្រាប់ឆ្នាំ២០១៥ ( Government Procurement Seminar for FY2015 )។

- ថ្ងៃទី២៥-២៦ មេសា ៖ បានចូលរួមរៀបចំ The First Cambodia Festival 2015 នៅ YOYOGI Park ដែលមានសមាសភាពចូលរួមពី តំណាងស្ថានទូតកម្ពុជា សហគមន៍ និងសមាគមនិស្សិតកម្ពុជានៅប្រទេសជប៉ុន និងអ្នកស្ម័គ្រចិត្តជប៉ុន។

- ថ្ងៃទី២៨ មេសា ៖ បានចូលរួមក្នុង Symposium 2015 ដើម្បីរំលឹកខួបលើកទី២៥ សម្រាប់ Council & Better Corporate Citizenship ( CBCC )។

សូម **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជារបាយការណ៍ និងទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំបាទ។

បានឃើញ និងគោរពជូន
**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** មេត្តាជ្រាបជា
របាយការណ៍ដ៏ខ្ពង់ខ្ពស់។

**ធូរ សុធីរ**
**ភារធារីស្តីទី**

អ្នកធ្វើរបាយការណ៍
ទីប្រឹក្សាពាណិជ្ជកម្ម

**ឡៅ ងួន អេង**

__ចម្លងជូន:__
-ក្រសួងពាណិជ្ជកម្ម
-ឯកសារ-កាលប្បវត្តិ